# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ

## ក្នុងទិវាមហាករុណាទិគុណសម្រាប់អ្នកជំងឺនិងជនពិការ

## នៅព្រះសហគមន៍សន្ដ:សិលា និង សន្ដ:ប៉ូល ភ្នំពេញថ្មី

## ថ្ងៃទី ១២ មិថុនា ឆ្នាំ ២០១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃអាទិត្យមុន ព្រះសហគមន៍យើងបានទទួលកូនៗប្រាំនាក់ ដែលទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ដ ហើយនៅថ្ងៃនេះ យើងបានទទួលកូនៗបីនាក់ទៀត ដែលទទួលអគ្គសញ្ញាជ្រមុជទឹក។ ថ្ងៃនេះយើងបានស្ដាប់អត្ថបទទីពីររបស់សន្ដ: ប៉ូល ដែលថែងថា "ដូច្នេះមិនមែនខ្ញុំទេដែលរស់នៅ គឺព្រះគ្រីស្ដទេតើដែលរស់នៅក្នុងខ្ញុំ..." ណែនាំឲ្យយើងយល់អត្ថន័យយ៉ាងជ្រៅអំពីអគ្គសញ្ញាជ្រមុជទឹកដែលយើងទទួលជីវិតថ្មីពីព្រះយេស៊ូ មានន័យថាព្រះយេស៊ូគង់នៅក្នុងយើង ហើយយើងតែមួយជាមួយនឹងព្រះអង្គ យើងរួមស្លាប់រួមរស់ជាមួយព្រះអង្គ។ ពេលទទួលអគ្គសញ្ញាជ្រមុជទឹក ប្រេងដែលយើងទទួលជាសញ្ញាថាយើងទទួលកម្លាំងពីព្រះយេស៊ូ។ អាវសដែលយើងទទួល បង្ហាញថារូបកាយរបស់យើង ជីវិតរបស់យើងរួមតែមួយជាមួយព្រះយេស៊ូ យើងបំពាក់ព្រះយេស៊ូហើយ។ ទៀនឆេះដែលយើងទទួល គឺជាពន្លឺរបស់ព្រះយេស៊ូដែលបំភ្លឺជីវិតរបស់យើង ឲ្យដឹងថាយើងមិនរស់នៅដូចពីមុនទៀតទេ។ ចំពោះបងប្អូនយើងមួយចំនួនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលពេញវ័យ នោះបងប្អូនចាំច្បាស់អំពីជីវិតមុននិងក្រោយពេលទទួលអគ្គសញ្ញា។ ប៉ុន្តែសម្រាប់កូនៗដែលទទួលអគ្គសញ្ញាជ្រមុជទឹកនៅថ្ងៃនេះ គេនៅក្មេងណាស់ ការរស់នៅរបស់គេតទៅមុខ គឺសង្ឃឹមលើឪពុកម្ដាយធម៌ដែលត្រូវជួយមើលកូនធម៌របស់ខ្លួន រួមជាមួយនឹងឪពុកម្ដាយបង្កើតដែលត្រូវអប់រំកូនៗ ឲ្យគេធ្វើដំណើររួមជាមួយនឹងព្រះយេស៊ូដែលបន្តិចម្ដងៗ ឲ្យគេចេះសូត្រធម៌បពិត្រព្រះនាងម៉ារី ធម៌ឱព្រះបិតា និងពេលគេធំបន្តិច ណែនាំឲ្យគេទៅទទួលការអប់រំនៅព្រះសហគមន៍របស់ខ្លួន ហើយពេលគេធំឡើង នោះគេនឹងហ៊ាននិយាយថា "មិនមែនខ្ញុំទេដែលរស់នៅ គឺព្រះយេស៊ូទេតើដែលគង់នៅក្នុងខ្ញុំ..." ដូចសន្ដ:ប៉ូលបានមានប្រសាសន៍ដែរ។

ថ្ងៃនេះជាទិវាព្រះមហាករុណាទិគុណសម្រាប់អ្នកជំងឺ ក្នុងឆ្នាំព្រះមហាករុណាទិគុណ គឺជាឱកាសមួយដើម្បីឲ្យយើងស្ដាប់ព្រះបន្ទូលដំណឹងល្អ ដែលបង្ហាញអំពីរបៀបព្រះបិតាស្រឡាញ់យើង ឲ្យយើងដឹងថានៅពេលណាយើងសម្លឹងមើលព្រះយេស៊ូ នោះគឺយើងមើលឃើញព្រះបិតា ហើយយើងជាផ្លូវតែមួយជាមួយព្រះយេស៊ូដោយសារយើងស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ។ ឆ្នាំនេះព្រះសហគមន៍អញ្ជើញយើងឲ្យមានចិត្តមេត្តាករុណា ដូចព្រះបិតាដែលមានព្រះហឫទ័យមេត្តាករុណា។ សប្ដាហ៍មុនព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ស្ដ្រីមេម៉ាយម្នាក់ថា៖ "កុំយំអីនាងអើយ..."។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ

ពាក្យ "កុំយំអី! កុំពិបាកចិត្តអី! កុំបាក់ទឹកចិត្តអី!" មានអត្ថន័យណាស់សម្រាប់យើងជាគ្រីស្តបរិស័ទ។ នៅថ្ងៃនោះ ស្ត្រីដែលមានបាបពេញខ្លួនបានមកជួបព្រះយេស៊ូនៅផ្ទះលោកស៊ីម៉ូនសិលា។ ពេលនោះនាងបានចូលទៅទៀបនឹងព្រះបាទាព្រះអង្គ ហើយនាងបានលាងព្រះបាទាព្រះអង្គដោយប្រេងក្រអូប និងនាងជូតព្រះបាទាព្រះអង្គដោយសក់របស់នាងទៀតផង។ នៅពេលនោះនាងយំខ្លាំងណាស់ដោយមានមូលហេតុពីរយ៉ាងគឺ៖ ទីមួយព្រោះនាងនឹកឃើញដល់បាបរបស់ខ្លួន និងទីពីរព្រោះនាងនឹកឃើញដល់ព្រះហឫទ័យប្រណីសន្តោសដ៏លើសលប់របស់ព្រះយេស៊ូចំពោះនាង ព្រះអង្គស្វាគមន៍នាង ព្រះអង្គមិនបដិសេធនាងដូចសង្គមដែលគេបដិសេធនាងទេ។ ភ្លាមនោះដែរ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ "នាងអើយ ខ្ញុំលើកលែងទោសឲ្យនាងបានរួចពីបាបហើយ ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមនាងអញ្ជើញទៅវិញដោយសេចក្តីសុខសាន្ត..." នេះជាព្រះបន្ទូលដែលពោរពេញដោយព្រះហឫទ័យប្រណីសន្តោសដែលយើងចង់បានបំផុត។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ សូមឲ្យយើងជាគ្រីស្តបរិស័ទប្រកាសជំនឿដូចសន្តៈប៉ូលប្រកាសដែរថា៖ "មិនមែនខ្ញុំទេដែលរស់នៅ គឺព្រះយេស៊ូគ្រីស្តទេដែលគង់នៅក្នុងខ្ញុំ..." ហើយសូមឲ្យយើងធ្វើសញ្ញាសម្គាល់នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់អ្នកដទៃផង។

យប់មិញនេះ នៅភូមិសុខសាន្ត យើងបានប្រមូលប្រជាជនប្រមាណជាង ៩៥០ នាក់ចូលរួមក្នុងពិធីជប់លៀងកសាងសុខសន្តិភាពក្នុងភូមិ ដែលមានគ្រីស្តបរិស័ទ មានអ្នកជំងឺអេដស៍ មានជនពិការ មានកូនៗមត្តេយ្យនិងអាណាព្យាបាលរបស់គេ មានអ្នកភូមិ មានឪពុកម្តាយរបស់អ្នកពិការនិងអ្នកជំងឺ... បងប្អូនទាំងអស់គ្នា បានរៀបចំខ្លួនយ៉ាងស្អាតបាតទាំងបង្ហាញអារម្មណ៍ថាគេមានភាពកក់ក្តៅ មានសេចក្តីសុខសាន្តក្នុងចិត្ត គេជាមនុស្សមានតម្លៃ ដោយសារគេបានទទួលសេចក្តីស្រឡាញ់ ទទួលធម៌មេត្តាករុណាពីព្រះជាម្ចាស់តាមរយៈកាយវិការរបស់យើងជាព្រះសហគមន៍។ ទាំងអស់នេះគឺជាអ្វីដែលយើងជាព្រះសហគមន៍ចង់ជូនទៅបងប្អូនយើង ដូចព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ស្ត្រីមានបាបម្នាក់នោះថា៖ "សូមនាងអញ្ជើញទៅវិញដោយសេចក្តីសុខសាន្ត..."។ ដូច្នេះ តើធ្វើដូចម្តេចដើម្បីយើងកសាងសេចក្តីសុខសាន្ត? តើធ្វើដូចម្តេចដើម្បីយើងបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់បងប្អូនយើង?

សម្រាប់យើងជាព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញ នៅគ្រប់ទីកន្លែងដែលយើងមានវត្តមាន នោះសូមឲ្យយើងទៅជាភូមិសុខសាន្តយ៉ាងតូចមួយដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គឺមានន័យថា យើងត្រូវយកចិត្តទុកដាក់ដល់មនុស្សទាំងឡាយដែលគ្មានទីពឹង ដែលសង្គមមើលមិនឃើញ យកចិត្តទុកដាក់នឹងមនុស្សចាស់ជរា ជនពិការធ្ងន់ដែលគ្មានអ្នកថែទាំជាដើម។ល។ យើងត្រូវយកចិត្ត

ទុកដាក់លើអាទិភាពទាំង ៧ ដែលមានដូចជា៖ ១/ ការអប់រំ, សុខភាព, ជនពិការ, ពលករ, ការការពារធម្មជាតិ , ការណែនាំឲ្យអ្នកក្រីក្រចូលក្នុងសង្គម, និងវិស័យអន្តរសាសនា។ យើងត្រូវខិតខំធ្វើ ដើម្បីឲ្យគ្រប់ទីកន្លែងដែលយើងរស់នៅមានសន្តិភាព មានសេចក្តីស្រឡាញ់ មានគ្រប់លក្ខណៈសម្បត្តិមកពីព្រះជាម្ចាស់។ យើងត្រូវខិតខំឲ្យព្រះសហាគមន៍របស់យើងទៅជាភូមិសុខសាន្តដ៏តូចមួយ ដែលណែនាំឲ្យគេមើលឃើញថា ពិតមែនព្រះយេស៊ូបានប្រទានសេចក្តីសុខសាន្តដល់គេ ដោយសារខ្លួនគេផ្ទាល់បានកសាងជីវិតយ៉ាងពិតប្រាកដ ដែលគេអាចធ្វើដំណើរទៅមុខបាន ដូចកាលពីដើមដែលព្រះអង្គមានព្រះបន្ទូលទៅស្ត្រីមានបាបថា "សូមនាងអញ្ជើញទៅវិញដោយសេចក្តីសុខសាន្ត..."។ យើងអាចជួយកសាងជីវិតរបស់បងប្អូនបាន គឺដោយសារយើងចូលនៅក្នុងសង្គម យើងចូលក្នុងក្រុមផ្សេងៗដើម្បីជួយសង្គមឲ្យបង្កើតទំនាក់ទំនងគ្នាយ៉ាងពិតៗ។ ពេលមានជនពិការ អ្នកជំងឺ អ្នកគ្មានទីពឹង អ្នកភូមិ សិស្សសាលា ...បានហូបបាយទាំងអំណរសប្បាយជាមួយគ្នា នោះពិតមែនគឺយើងបានណែនាំឲ្យពួកគេចូលនៅក្នុងសង្គមយ៉ាងពិតប្រាកដ ជាក្រុមគ្រួសារតែមួយ។ ខ្ញុំសង្ឃឹមថា ភូមិភាគភ្នំពេញយើងក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ នឹងទៅជាឆ្នាំដែលមានផលផ្លែយ៉ាងច្រើន ដោយសារមានព្រះយេស៊ូគង់នៅជាមួយទាំងមានព្រះបន្ទូលមកយើងថា៖ "សូមចេញទៅ! ដោយសារអ្នកបានទទួលជីវិតថ្មី និងបានទទួលសេចក្តីសុខសាន្តហើយ"។

សូមព្រះបិតាជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រទានពរដល់យើងខ្ញុំទាំងអស់គ្នាដែលជាជនពិការ ជាអ្នកជំងឺ ជាមនុស្សគ-ថ្លង់ ជាមនុស្សមានសុខភាពធម្មតា ឲ្យយើងខ្ញុំដឹងថា យើងខ្ញុំទាំងអស់គ្នាជាក្រុមគ្រួសារតែមួយ ដែលព្រះជាម្ចាស់ណែនាំឲ្យយើងខ្ញុំធ្វើជាបងប្អូនគ្នាក្នុងអង្គព្រះគ្រីស្ត ដែលពោរពេញដោយសេចក្តីស្រឡាញ់ និងពោរពេញដោយអំណរសប្បាយ។

ថ្ងៃនេះ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា សម្រាប់ព្រះសហាគមន៍ដែលព្រះយេស៊ូបានប្រោសប្រទានឲ្យយើងខ្ញុំ សម្រាប់កម្លាំងដែលយើងខ្ញុំបានទទួលពីព្រះអង្គ។ សូមអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា ដែលគង់នៅជាមួយយើងខ្ញុំជានិច្ច។ អាម៉ែន។